**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកែប**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ : ...០១៥.../១៦.សជណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការងារជួសជុលផ្លូវលេខ២៣១៧ ( ហៅផ្លូវ៣០ម៉ែត្រ ) ដោយចាក់កៅស៊ូ DBST ដែលមានផ្ទៃក្រឡាសរុប ២១.៩៥៤ម៉ែត្រការ៉េ និងដាក់លូឆ្លងកាត់ផ្លូវ ចំនួន៦កន្លែងដែលមានមុខកាត់១ម៉ែត្រប្រវែងសរុប១៥៣ម៉ែត្រ ជូនសាលាខេត្តកែប ឆ្នាំ២០១៦

ខេត្តកែប សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា ខេត្តកែប នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារជួសជុលផ្លូវលេខ២៣១៧ (ហៅផ្លូវ៣០ម៉ែត្រ) ដោយចាក់កៅស៊ូDBST ដែលមានផ្ទៃក្រឡាសរុប ២១.៩៥៤ម៉ែត្រការ៉េ ចំណុចទី១ចាប់ពីផ្លូវកៅស៊ូមុខវត្តសមុទ្ររង្សីទល់ចំណុចប្រសព្វផ្លូវលេខ ២៣១៧ ប្រវែង២៨៨មែត្រ គុណ ៩,៥ម៉ែត្រ ស្មើ២.៧៣៦ម៉ែត្រការ៉េ ចំណុចទី២ ចាប់ពីផ្លូវលេខ២៣០០ មកដល់ផ្លូវប្រសព្វចុះពីវត្តសមុទ្ររង្សីប្រវែង៤៤២ម៉ែត្រ គុណ ១២ម៉ែត្រស្មើ៥.៣០៤ម៉ែត្រការ៉េ ចំណុចទី៣ចាប់ពីផ្លូវប្រសព្វឆ្ពោះទៅផ្លូវបំបែកឡើងវត្តវិបសេនាធុរៈ ប្រវែង៧៧៣ម៉ែត្រ គុណ ១៨ម៉ែត្រ ស្មើ១៣.៩១៤ម៉ែត្រការ៉េ និងដាក់លូឆ្លងកាត់ផ្លូវ ចំនួន៦កន្លែងដែលមានមុខកាត់១ម៉ែត្រប្រវែងសរុប១៥៣ម៉ែត្រ ជូនសាលាខេត្តកែប ឆ្នាំ២០១៦។

ខេត្តកែប បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្ម ដែលមានអាសយដ្ឋានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកែប ចាប់ពីថ្ងៃទី ២៥..... ខែ កក្កដា.....ឆ្នាំ២០១៦ តទៅ រៀងរាល់ម៉ោងធ្វើការ ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី...៣១..... ខែ.សីហា.........ឆ្នាំ២០១៦ វេលាម៉ោង .០៩:០០...........។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង០៩:០០ ថ្ងៃទី .៣១..... ខែ .សីហា........... ឆ្នាំ២០១៦ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅកែប ថ្ងៃទី ...១៩... ខែ កក្កដា.. ឆ្នាំ២០១៦
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ចម្លងជូន ៖
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ